# ក្រុមហ៊ុន ជីនវីន អ៊ិនដាសស្ទ្រី (ខេមបូឌា) ខូអិលធីឌី

GINWIN INDUSTRY ( CAMBODIA ) CO., LTD

## កិច្ចព្រមព្រៀង

ស្តីពីកិច្ចប្រជុំពិភាក្សាលើករណីស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល១ខែ គឺ

ចាប់ពីថ្ងៃទី ១៥ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២០ ថ្ងៃសុក្រ ខែពិសាខ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ វេលាម៉ោងប្រាំបួនព្រឹក មានកិច្ចប្រជុំមួយនៅក្រុមហ៊ុន ជីនវីន អ៊ិនដាសស្ទ្រី (ខេមបូឌា) ខូអិលធីឌី មានអាសយដ្ឋានស្ថិតនៅភូមិព្រៃចាស់ ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដែលមានចំនួនកម្មករសរុបចំនួន១៧០៧នាក់ (ស្រី១៦២៩នាក់) ក្នុងចំណោមកម្មករ១៧០៧នាក់ (ស្រី១៦២៩នាក់) មាននាយក ឈ្មោះ WANG MENGJIN ជនជាតិចិន ជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ ដែលមានលោក MIAO XUENAN ជាតំណាងនាយកប្រចាំក្រុមហ៊ុនបានចូលរួមប្រជុំពិភាក្សាលើករណី ស្តីពីការស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិតរយៈពេល១ខែ។

ជាកិច្ចចាប់ផ្តើមលោក MIAO XUENAN ជាប្រធានអង្គប្រជុំបានបើកកិច្ចប្រជុំនិងថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅ ដល់អស់លោក លោកស្រីដែលបានអញ្ជើញចូលរួមប្រជុំថ្ងៃនេះ បន្ទាប់មកលោកប្រធានអង្គប្រជុំមានមតិសម្របសម្រួលអំពី ករណីខាងលើ និងពន្យល់ពីមូលហេតុដោយសារតែក្រុមហ៊ុនខ្វះវត្ថុធាតុដើមសំរាប់ផលិត និងដោយសារម្ចាស់ទំនិញបានពន្យាពេលទិញទំនិញក្នុងកំឡុងពេលផ្ទុះមេរោគ ឆ្លងជា សាកលកូវីដ-១៩ ដូចនេះ ក្រុមហ៊ុន ជីនវីន អ៊ិនដាសស្ទ្រី (ខេមបូឌា) ខូអិលធីឌី និងកម្មករនិយោជិតទាំងអស់ បានព្រមព្រៀងគ្នាដូចខាងក្រោម:

១-ឯកភាពព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន២៥៣ (ស្រី២២៨នាក់) រយៈពេល១ខែ ដោយគិតចាប់ពីថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០ ដល់ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២០។

២-ក្នុងកំឡុងពេលនៃការព្យួរកិច្ចសន្យាការងារនេះភាគីទាំងពីរបានឯកភាពអនុវត្តន៍តាមសេចក្តីណែនាំរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ។

ខេត្តកណ្តាលថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

**បានឃើញនិងឯកភាព**

**តំណាងកម្មករនិយោជិត**

ជា ជួន
ឈិត ធាវ៉ា
សុន លីមហុង
ហៃ ស្រីលាក់
គីម ស៊ុនរី
អ៊ឹម គឹមសួរ
ឃិន សុខា
រស់ ដានី
អ៊ុតចន្ធី
ចន្ថា ចន្ទី

**តំណាងក្រុមហ៊ុន**

ជីនវីន
អ៊ិនដាសស្ទ្រី (ខេមបូឌា)
GINWIN INDUSTRY (CAMBODIA) CO., LTD

Scanned with CamScanner